**MEDIA ADVISORY**

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# "ការពិគ្រោះយោបល់ពេញលេញជាសាធារណៈ អំពីច្បាប់បោះឆ្នោត មានសារៈសំខាន់ណាស់ សម្រាប់អនាគតនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា" - នេះបើតាមប្រសាសន៍របស់អ្នកជំនាញការសិទ្ធិមនុស្ស អ.ស.ប

ទីក្រុងហ្សឺណែវ (៩ មីនា ២០១៥) - អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទស៊ូប៊ែឌី នៅថ្ងៃនេះ បានស្វាគមន៍ការសម្រេចរបស់សភាកម្ពុជា ដើម្បីរៀបចំឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈមួយលើសេចក្តីព្រាងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច្បាប់បោះឆ្នោត) និងសេចក្តីព្រាងច្បាប់ស្តីពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ថាជា "ការរងចាំដ៏យូរ និងជាជំហានដ៏សំខាន់សម្រាប់អនាគតនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា"។

លោក ស៊ូប៊ែឌី បានមានប្រសាសន៍ "ច្បាប់បោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ធ្វើនិយតកម្មដំណើរការការបោះឆ្នោតនៅកម្ពុជា"។ "ការបោះឆ្នោតបានមានជាប្រវត្តិសាស្ត្រតាំងពីដើមដំបូងមក គឺមិនត្រឹមតែជាជម្លោះនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការរំលោភសិទ្ធិមនុស្សរាប់មិនអស់ ក្នុងរយៈកាលកន្លងមក"។
ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានធ្វើឡើងក្នុងខែកក្កដា ឆ្នាំ២០១៣ ត្រូវដិតដាមដោយការចោទប្រកាន់ពីភាពមិនប្រក្រតីនៃការបោះឆ្នោត។ ក្នុងចំណោមការអំពាវនាវឲ្យមានការស៊ើបអង្កេតមួយប្រកបដោយឯករាជ្យ និងអាចជឿទុកចិត្តបាន លើករណីចោទប្រកាន់ដោយគណបក្សប្រឆាំង ប្រទេសនេះត្រូវបានលេបត្របាក់ដោយការជាប់គាំងផ្នែកនយោបាយ ដែលទើបនឹងបានដោះស្រាយនៅក្នុងខែសីហាឆ្នាំ ២០១៤។

អ្នកជំនាញការឯករាជ្យ បានគូសបញ្ជាក់អំពីវប្បធម៌វិជ្ជមាននៃការសន្ទនារវាងគណបក្សធំៗទាំងពីរដែលបានឈានដល់ការព្រមព្រៀងគ្នាមួយលើអត្ថបទដ៏សំខាន់នេះ ទោះជាយ៉ាងណាក៏ដោយ លោកបានសង្កត់ធ្ងន់ថា "ភាគីទាំងអស់ មិនត្រូវផ្តោតការចរចាឲ្យឃ្លាតឆ្ងាយពីបទដ្ឋានសិទ្ធិមនុស្សជាតិ និងអន្តរជាតិឡើយ"។

ក្នុងន័យនេះ អ្នករាយការណ៍ពិសេស បានកត់សម្គាល់ថា តួអង្គសង្គមស៊ីវិលនៅកម្ពុជា បានសម្តែងកង្វល់ជាខ្លាំងអំពីចំណុចជាច្រើន ដែលគេរាយការណ៍ថាបានយល់ព្រមទទួលយក។

លោក ស៊ូប៊ែឌី បានមានប្រសាន៍ថា "គួរឲ្យសោកស្តាយដែលថា សេចក្តីព្រាងច្បាប់នេះ ត្រូវបានចែករំលែកនៅពេលល្ងាចមុនថ្ងៃដំណើរការពិគ្រោះយោបល់នេះ ដែលធ្វើឲ្យសង្គមស៊ីវិល និងស្ថាប័នដទៃទៀតដែលមានចំណាប់អារម្មណ៍លើបញ្ហានេះ បាត់បង់លទ្ធភាពពិនិត្យច្បាប់នេះឲ្យបានស៊ីជម្រៅ និងរួមចំណែកប្រកបដោយអត្ថន័យដល់ការពិគ្រោះយោបល់នេះ"។

អ្នករាយការណ៍ពិសេស បានធ្វើការសន្និដ្ឋានថា "ដំណើរការពិគ្រោះយោបល់នេះ ត្រូវតែបន្តធ្វើដោយទុកពេលវេលាគ្រប់គ្រាន់ អាចឲ្យអ្នកទាំងឡាយចូលរួមផ្តល់មតិយោបល់របស់ខ្លួនលើច្បាប់ទាំងនោះ ដើម្បីអាចឲ្យសភា ផ្តើមជជែកពិភាក្សាដោយមានព័ត៌មានគ្រប់គ្រាន់  មុននឹងឈានទៅអនុម័តច្បាប់ដ៏សំខាន់ទាំងនេះ"
។

# ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយ ការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គលឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោក ផ្ទាល់។ បច្ចុប្បន្ន លោកជាសាស្ត្រាចារ្យនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវី អាជីពមួយរូបនៃគណៈ មេធាវីមីឌឹលថឹមភឹល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ាននៃនីតិអន្តរ ជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹងគម្រោងសំខាន់ៗ ទស្សនាវដ្តីអាស៊ាននៃច្បាប់អន្តរជាតិ ដោយការិយា ល័យព័ត៌មាននៃសាកលវិទ្យាល័យខេមប្រីដជ៍។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*ដើម្បីអានរបាយការណ៍ចុងក្រោយបំផុត(A/HRC/24/36)របស់អ្នករាយការណ៍ពិសេស ដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស សូមចូលទៅកាន់គេហទំព័រ៖*
*http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*

*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមទាក់ទងមក ៖ កញ្ញា អ័លហ្គា ណាកាចូ (Ms. Olga Nakajo) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩២៨ ៩៣៤៨ / អ៊ីម៉ែល onakajo@ohchr.org) ឬ សរសេរមកកាន់ srcambodia@ohchr.org*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទងមកឈ្មោះ សាប៉ៀរ

សេលាយ៉ា (Xabier Celaya) សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ / អ៊ីម៉េល xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើបណ្តាញព័ត៌មានសង្គម ៖**

**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

**ទ្វីតធឺ៖** http://twitter.com/UNrightswire

**ហ្គោហ្គីល៖ Google+** gplus.to/unitednationshumanrights

**យូធូប៖** http://www.youtube.com/UNOHCHR

**ផែកលិបិក្រមសិទ្ធិមនុស្សជាសកល ៖** http://uhri.ohchr.org/en